ការិយាល័យកណ្តាល

អេស៊ីលីដា
ACLEDA BANK

# សេចក្តីជូនដំណឹង
# ស្តីពី
# ការឈប់សម្រាករយៈពេល ៣ថ្ងៃ
# សម្រាប់ការចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៃរដ្ឋសភា

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន និងវិនិយោគិនទាំងអស់ មេត្តាជ្រាបថា៖ ដោយអនុលោមតាមសេចក្តីណែនាំ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ: ០៤៥/២៣ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣ និងដើម្បីបង្កលក្ខណៈងាយស្រួល និងពេញលេញដល់គ្រប់កម្មករនិយោជិតក្នុងការចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា ដែលនឹងប្រព្រឹត្តទៅនាថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា នឹងឈប់សម្រាក និងផ្អាកប្រតិបត្តិការបម្រើសេវាជូនអតិថិជន និងសាធារណជនទូទៅតាមបញ្ជរ ចំនួន ៣ថ្ងៃ ចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៣ លើកលែងធនាគារ អេស៊ីលីដា សាខាសុធារស (ផ្សារអ៊ីអន) សាខាសែនសុខ (ផ្សារអ៊ីអន) និងសាខាអ៊ីអនមានជ័យ នៅបើកបម្រើជាធម្មតា។ ចំពោះសេវាធនាគារអេឡិចត្រូនិកបើកបម្រើជាធម្មតាជូនអតិថិជន និងសាធារណជនទូទៅ ២៤ម៉ោងក្នុងមួយថ្ងៃ និង ៧ថ្ងៃ ក្នុងមួយសប្តាហ៍។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងវិនិយោគិនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន៕

ថ្ងៃចន្ទ ១៥រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣
**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA BANK PLC.

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP